ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សន្ទរកថាបិទអង្គសន្និសិទ្ធថ្ងៃទី ២៤ វិច្ឆិកា ឆ្នាំ ២០០៩ដោយ **ឯកឧត្តម ឡុង ណារ៉េត** រដ្ឋលេខាធិការក្រសួងប.ទ

- សូមគោរពឯកឧត្តម Kuroki Masafumi ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំកម្ពុជា
- សូមគោរពលោក Suzuki Yasujiro ប្រធានតំណាង JICA កម្ពុជា
- សូមគោរពឯកឧត្តម Kawauchi Masataka អគ្គនាយកនៃក្រសួងកិច្ចការផ្ទៃក្នុង និង គមនាគមន៍ជប៉ុនព្រមទាំងប្រតិភូជប៉ុនទាំងអស់
- សូមគោរព ឯកឧត្តមរដ្ឋលេខាធិការ អនុលេខាធិការ
- លោក លោកស្រី ជាទីគោរព

តាងនាមអោយថ្នាក់ដឹកនាំ និងមន្ត្រីក្រសួង ប.ទ ទាំងអស់ព្រមទាំងអង្គពិធីទាំងមូល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រៅជ្រះចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលបានចូលរួមក្នុងអង្គសន្និសិទ្ធ នេះអស់រយៈពេលពេញមួយថ្ងៃមកហើយ។

សន្និសិទ្ធដែលបានរៀបចំរួមគ្នារវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងកិច្ចការផ្ទៃក្នុងនិងគមនាគមន៍ជប៉ុននៅថ្ងៃនេះគឺជាកិច្ចសហប្រតិបត្តការដ៏ល្អ មួយនិងលើកដំបូងចាប់តាំងពីបានចុះហត្ថលេខារួមគ្នាមួយកាលពីខែ ឧសភា ឆ្នាំ ២០០៩ មក។ កិច្ចប្រជុំនាថ្ងៃនេះបានឆ្លុះបញ្ចាំងអោយឃើញពីការអភិវឌ្ឍន៍លើវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ដែលបានរីកចំរើនជាលំដាប់។ ជាការពិតណាស់ការអភិវឌ្ឍន៍រីកចម្រើនវិស័យនេះគឺស្តែង ចេញពីការខិតខំប្រឹងប្រែងអនុវត្តន៍ គ្រប់បែបយ៉ាងជាមួយនិងបច្ចេកវិទ្យាទំនើប និង បទពិសោធន៍ដ៏ល្អៗ ជាក់ស្តែងថ្ងៃនេះបានផ្តល់អនុសាសន៍ដ៏ល្អមកពីក្រសួង **ប.ទ** ក្រសួងកិច្ចការផ្ទៃក្នុងនិងគមនាគមន៍ជប៉ុន និងប្រតិបត្តិករនៃប្រទេសទាំងពីរ។ ទាំងនេះសុទ្ធសឹងជាវិភាគទានដ៏ធំមួយសំរាប់ការចូលរួមកសាងពង្រីកបន្ថែម និង កែតំរូវលើការគ្រប់គ្រងការរៀបចំគោលនយោបាយ ដើម្បីឆ្លើយតបនូវ

តំរូវការសេវាបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ជូនប្រជាពលរដ្ឋអោយមានប្រសិទ្ធភាពខ្ពស់ មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ជាមួយ និងតំលៃថោកសមរម្យប្រកបដោយគុណភាពខ្ពស់។

ដូចដែល ឯកឧត្តម លោកជំទាវ លោក លោកស្រី បានជ្រាបហើយថាវិស័យ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍នៅកម្ពុជាក៏ដូចជាទូទាំងពិភពលោក គឺ ជាកត្តាចំបងមួយបំរើអោយវិស័យសេដ្ឋកិច្ចសង្គមរួមមានការអភិវឌ្ឍន៍លឿនបំផុតនៅក្នុងយុគសម័យ បច្ចេកវិទ្យា IP យើងនេះ។ ឆ្លងតាមអង្គសន្និសិទ្ធនាថ្ងៃនេះ យើងឃើញថាការរីកចំរើននៃបច្ចេកវិទ្យា IP ជាមួយនឹងរលកអាកាសវិទ្យុសេវា បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ចល័តមានការកើនឡើងខ្ពស់បំផុត។ បណ្តាញកាប្លិ៍អុបទិកមានតភ្ជាប់គ្រប់ខេត្ត -ក្រុង មានបណ្តាញ Internet ប្រើប្រាស់ជាមួយល្បឿនលឿន និងមានកម្មវិធីប្រើប្រាស់ជាច្រើន។ បទពិសោធន៍ដ៏ល្អដែលបានលើកឡើងដោយប្រតិភូជប៉ុន បានឆ្លុះបញ្ចាំងអំពីការរីកចំរើនលើគ្រប់ សេវានៃវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍នៅប្រទេសជប៉ុនព្រមទាំងលទ្ធផលជាវិជ្ជមានដែលប្រតិបត្តិករទទួលបានកន្លងមកជាមួយនឹងការ រៀបចំការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដ៏ល្អសំដៅបំរើប្រជារាស្ត្រ និង រក្សាស្ថានភាពសេដ្ឋកិច្ចដែលបច្ចុប្បន្នពិភពលោកកំពុងជួបវិបត្តិ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!**

ការរីកចំរើនដ៏ឆាប់រហ័សលើវិស័យ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ នោះតម្រូវឱ្យមានការរៀបចំគោលនយោបាយ ច្បាប់ និងបញ្ញត្តិកម្មស្តីពីវិស័យទូរគមនាគមន៍ ឱ្យបានត្រឹមត្រូវមានតម្លាភាពច្បាស់លាស់សំរាប់គ្រប់គ្រងបណ្តាញ និងសេវាទូរគមនាកមន៍ក្នុងប្រទេស។ ប្រទេសកម្ពុជាកំពុងរៀបចំច្បាប់ស្តីពីទូរគមនាគមន៍ ដែលជាកត្តាសំខាន់បំផុតក្នុងការចូលរួមអនុវត្តប្រកបដោយយុត្តិធម៌មានស្ថេរភាពក្នុងការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍នៅកម្ពុជា។ ឆ្លៀតក្នុងឱកាសនេះខ្ញុំសូមលើកឡើងអំពីគោលបំណង និងសារៈសំខាន់នៃការរៀបចំគោល នយោបាយនឹងការអភិវឌ្ឍន៍ទីផ្សារ និងសេវា បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍នៅកម្ពុជាគឺ សំដៅជំរុញការគ្រប់គ្រងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ឱ្យមានប្រសិទ្ធភាព ស្ថេរភាពស្របតាមតំរូវការទីផ្សារបច្ចុប្បន្ន និងទៅអនាគត។ ទស្សនៈទានដ៏ល្អដែលជួយដល់សន្និសិទ្ធនេះនឹងជួយជំរុញ និងលើកកំពស់ការបំរើសេវាបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ និងការកសាងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាពនឹងជោគជ័យជាលក្ខណៈអន្តរជាតិដែលបានមកពីការគ្រប់គ្រង និងការអនុវត្តន៍តាមគោលនយោបាយ និងបញ្ញត្តិកម្មច្បាស់លាស់។

ក្នុងន័យនេះខ្ញុំសូមអោយអង្គសន្និសិទ្ទទាំងមូលចូលរួមដកស្រង់បទពិសោធន៍ដ៏ល្អៗនោះដើម្បីចូលរួមបំពេញការរៀបចំគោលនយោបាយបញ្ញត្តិកម្មនិងការអភិវឌ្ឍន៍ទីផ្សារប្រកបដោយជោគជ័យ និងមានតម្លាភាព ។ ទន្ទឹមនឹងនោះ ខ្ញុំសង្ឃឹមផងដែរថា ជាមួយនឹងការខិតខំប្រឹងប្រែងទទួលយកនូវបទពិសោធន៍ទាំងនោះ និងការជួយឧបត្ថម្ភគាំទ្រពីក្រសួង កិច្ចការផ្ទៃក្នុង និងគមនាគមន៍ជប៉ុន ដើម្បីជំរុញការបណ្តុះបណ្តាលមន្រ្តីទៅតាមជំនាញនៃការគ្រប់គ្រងអោយមានគុណភាពល្អៗ

ជាទីបញ្ចប់ អង្គសន្និសិទ្ទនាថ្ងៃនេះ និងនាំយកនូវចំណេះដឹងព្រមទាំងបទពិសោធន៍ដ៏ល្អដែលជាទុនសំរាប់ការរៀបចំអភិវឌ្ឍន៍លើវិស័យ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍នៅកម្ពុជាព្រមទាំងការពង្រឹងកិចសហប្រតិបត្តិការដ៏ល្អរវាងក្រសួង **ប.ទ** និង ក្រសួង កិច្ចការផ្ទៃក្នុង និងគមនាគមន៍ ជប៉ុនទៅអនាគតៗ

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ជប៉ុន ឯកឧត្តម ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំកម្ពុជា ឯកឧត្តម លោកជំទាវ លោកអគ្គនាយក និង ប្រតិភូជប៉ុននៃក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ជប៉ុនដែលបានចូលរួមសហការ និង ជួយឧបត្ថម្ភគ្រប់បែបយ៉ាង ធ្វើអោយកម្មវិធីនាថ្ងៃនេះបានទទួលជោគជ័យប្រកបដោយផ្លែផ្កាៗ

ខ្ញុំសូមជូនពរអោយឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់បានជួបតែសេចក្តីសុខ សេចក្តីចំរើន ជានិរន្តិ៍ កុំបីឃ្លៀងឃ្លាតឡើយៗ

ជាបន្តនេះខ្ញុំសូមប្រកាសបិទអង្គសន្និសិទ្ទជាផ្លូវការពីពេលនេះៗ

***សូមអរគុណ...!***